អង្គការអប់រំពិភពលោក
WORLD EDUCATION

# គម្រោងស្បៀងអាហារសម្រាប់ការអប់រំ

# ប័ណ្ណណែនាំអំពីរបៀបដឹកនាំ ការសរសេរដោយឯករាជ្យ

## ការសិក្សាស្រាវជ្រាវ

ការសរសេរប្រហែលជាស្មុគស្មាញជាងគេក្នុងចំណោមបំណិនទាំងបួន គឺបំណិននិយាយ បំណិនស្តាប់ បំណិនអាន និងបំណិនសរសេរ។

ការនិយាយ និងការស្តាប់ មនុស្សទទួលបានដោយឯកឯងជាធម្មជាតិតាមរយៈការប្រាស្រ័យទាក់ទង ហើយការនិយាយ និងការស្តាប់ ក៏ទទួលឥទ្ធិពលពីអ្នកប្រើប្រាស់ភាសានៅផ្ទះ នៅសាលា និងមជ្ឈដ្ឋានជុំវិញ។ បំណិនទាំងពីរនេះ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់បំណិនដទៃ។ ទោះជាយ៉ាងនេះក្តី ការអាន និងការសរសេរត្រូវតែមានការបង្រៀន។ បំណិនទាំងពីរនេះមានភាពស្មុគស្មាញ ហើយក៏ពុំមានក្រិតក្រមច្បាស់លាស់ដែរ។

| | **ផ្ទាល់មាត់** | **ជាអត្ថបទ** |
|---|---|---|
| **បំណិនទទួល** (Receptive Skills) | ការស្តាប់ | ការអាន |
| **បំណិនបញ្ចេញ** (Productive Skills) | ការនិយាយ | ការសរសេរ |

ការស្តាប់និងការអាន ពេលខ្លះត្រូវបានគេគិតថាជា បំណិនទទួលយក។ បំណិនទាំងពីរនេះ ទាក់ទងទៅនឹងគំនិតខាងក្នុង និងការបកស្រាយ ប៉ុន្តែអ្នកស្តាប់និងអ្នកអាន មិនត្រូវការបញ្ចេញសំដី ឬសរសេរជាអត្ថបទទេ។ ផ្ទុយទៅវិញ នៅក្នុងការនិយាយនិងសរសេរ មនុស្សត្រូវបង្ហាញសមត្ថភាពរបស់ពួកគេតាមរយៈសកម្មភាព។ ទាំងនេះហៅថា ជាការបញ្ចេញ(ផលិត)។

ការសរសេរ គឺជាបំណិនទីបួន ហើយវាប្រហែលជាបំណិនដែលពិបាកជាងគេ ក្នុងការរៀនភាសា។ ការសរសេរមានពីរប្រភេទគឺ ការសរសេរបែបតែងសេចក្តី និងការសរសេរបែបចម្លង។ អ្នកកង្កើតកម្មវិធីសិក្សា និងគ្រូបង្រៀន ត្រូវតែព្យាយាមធ្វើឱ្យមានតុល្យភាព រវាងទិដ្ឋភាពទាំងពីរនេះ។ វាមានភាពងាយស្រួលនៅពេលដែលយើងបង្រៀនផ្តោតទៅលើកាសរសេរបែបចម្លង (រាប់ទាំង អក្ខរាវិញ្ញាស សំណេរផ្ទាល់ដៃ និងវេយ្យាករណ៍) ដោយហេតុថា វាស្រួលបង្រៀន និងស្រួលវាយតម្លៃ។ កត្តានេះមានន័យថា យើងមិនបានយកចិត្តទុកដាក់ដល់ការសរសេរបែបតែងសេចក្តី។ តែទោះជាយ៉ាងនេះក្តី ការបង្រៀនសរសេរបែបចម្លង មិនបានជួយដល់ការអភិវឌ្ឍន៍របស់កុមារទេ។ ការបង្រៀនសរសេរបែបតែងសេចក្តី និងបែបចម្លង មានសារសំខាន់ដូចគ្នាចំពោះសិស្ស។

## <u>សេចក្តីណែនាំសម្រាប់ ការសរសេរដោយឯករាជ្យ</u>

1. អាននរឿងៗ នៅក្នុងថ្នាក់ហើយបង្ហាញរូបភាព
2. សិស្សអាចប្រើ ក្បាំងក្បាល ឬមួក ដើម្បីសំដែងឬនិទានរឿងឡើងវិញ។ ប្រសិនបើចាំបាច់ សិស្សអាចប្រើរូបភាពដើម្បីជួយរំលឹក។
3. ពិភាក្សាអំពីរូបភាពចុងបង្អស់ និងការបញ្ចប់រឿង។ តើពួកគេពេញចិត្តដែរឬទេ ឬក៏ចង់សរសេរការបញ្ចប់រឿងតាមរបៀបផ្សេងវិញ?
4. គ្រូឧទ្ទេស (គ្រូបង្រៀន) ធ្វើជាគំរូអំពីសកម្មភាព ការសរសេរបែបសហការដែលបង្ហាញពំពីអ្វីដែលត្រូវសរសេរ។ ឧទាហរណ៍: "ព្រះអង្គម្ចាស់ រ៉ូណាល់" ។ អ្នក (គ្រូបង្រៀន) សំដែងធ្វើជា ព្រះអង្គម្ចាស់ រ៉ូណាល់ តាមការនិយាយរបស់អ្នក។
5. បណ្ណ ***លក្ខណៈពិសេសរបស់របស់រឿង*** មានការផ្តល់សេចក្តីណែនាំជាច្រើនទាក់ទងនិងសកម្មភាពនៃការសរសេរ។

ខាងក្រោមនេះគឺជាអាស័យដ្ឋាន សម្រាប់អ្នកចូលទៅមើលវីដេអូអំពីការបង្រៀន ការសរសេរបែបឯករាជ្យ។

https://www.youtube.com/watch?v=HTbTnncg89c&list=PLlMfSiUPpWPEUVk4O9FyL3_OonTIcFVLr&index=7



